ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥ ២៦ ...សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រើប្រាស់ប្រាក់រង្វាន់នៃចំណូលប្រមូលដោយ
## អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

---

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៥២អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងលិខិតលេខ ៣៤២៤សហវ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុញ្ញាតប្រើប្រាស់ថវិការង្វាន់ នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

សម្រេច

**ប្រការ ១.-**

ថវិការង្វាន់ ១%នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលត្រូវបានកំណត់តាមបញ្ញត្តិលិខិតលេខ ៣៥២៥សហវ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ដូចតទៅ៖

- ៦៥%នៃថវិការង្វាន់ សម្រាប់ឧបត្ថម្ភជីវភាពមន្ត្រីរាជការគយនិងរដ្ឋាករទូទៅគ្រប់រូប ទៅតាមគោលការណ៍សមធម៌ និងគុណសម្បត្តិការងារ។

- ២០%នៃថវិការង្វាន់ សម្រាប់ចំណាយក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបំពាក់មធ្យោបាយប្រដេញ និងសម្ភារទូរគមនាគមន៍ តាមតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តាមបទបញ្ញត្តិជាធរមាន។

- ១០%នៃថវិការង្វាន់ សម្រាប់លើកទឹកចិត្តដល់អង្គភាព និងមន្ត្រីគាំទ្រដទៃទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមគោលការណ៍សមធម៌ និងគុណសម្បត្តិការងារ។

- ៥%នៃថវិការង្វាន់ ត្រៀមបំរុងក្នុងបេឡាសម្ងហភាព សម្រាប់ចំណាយលើការឧបត្ថម្ភមន្ត្រីរាជការគយនិងរដ្ឋាករ និងមន្ត្រីជាប់កិច្ចសន្យាក្នុងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានជួបប្រទះគ្រោះថ្នាក់ ឈឺថ្កាត់ ឬមហន្តរាយផ្សេងៗ ព្រមទាំងការចំណាយចាំបាច់ប្របាក់ប្រហែល តាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា។

**ប្រការ ២.-**

ថវិការង្វាន់ ៦៥%ដូចមានបញ្ញត្តិក្នុងប្រការ ១ នៃប្រកាសនេះ ត្រូវបានឧបត្ថម្ភជូនមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា ទៅតាមតួនាទី និងមេគុណសមាមាត្រ ដូចមានចែងក្នុងតារាងខាងក្រោម៖

| ល.រ | តួនាទី | មេគុណសមាមាត្រ |
|---|---|---|
| ១ | អគ្គនាយក | ៤.០០ |
| ២ | អគ្គនាយករង | ៣.៥០ |
| ៣ | ប្រធាននាយកដ្ឋាន | ៣.០០ |
| ៤ | អនុប្រធាននាយកដ្ឋាន | ២.៥០ |
| ៥ | ប្រធានការិយាល័យ | ២.០០ |
| ៦ | អនុប្រធានការិយាល័យ | ១.៥០ |
| ៧ | ភ្នាក់ងារ | ១.០០ |

**ប្រការ ៣.-**

ប្រគល់សិទ្ធិជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិការង្វាន់ ទៅតាមមេគុណសមាមាត្រ និងតាមមុខសញ្ញាដែលត្រូវបានទទួលថវិការង្វាន់ដូចមានបញ្ញត្តិក្នុងប្រកាសនេះ។

**ប្រការ ៤.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អាចដកថវិការង្វាន់ទាំងនេះបាន ពីប្រាក់ចំណូលពន្ធ អាករ ពិន័យ និងកម្រៃផ្សេងៗជាប្រចាំរបស់ការិយាល័យ សាខា នាយកដ្ឋាន ក្រោមឱវាទរបស់ខ្លួន នៅពេលមានតម្រូវការចាំបាច់ និងត្រូវរាយការណ៍រាល់ត្រីមាសនីមួយៗ ពីស្ថានភាពចំណូល និងចំណាយបេឡាថវិការង្វាន់ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យបានទៀងទាត់។

**ប្រការ ៥.-**

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

គាត ឈន់

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ